ផ្សារមូលបត្រកម្ពុជា

CSX

ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃ ព្រហ.១១រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*

*រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ ២០២១*

# សេចក្តីប្រកាសព័ត៌មាន

## ការទិញយកភាគហ៊ុនចំនួន ៤៥,០៩% នៃក្រុមហ៊ុន ភ្នំពេញអេសអ៊ីហ្សិត ភីអិលស៊ី ត្រូវបានធ្វើឡើងជាផ្លូវការនៅថ្ងៃនេះនៅ ផ្សារមូលបត្រកម្ពុជា

ថ្ងៃនេះ ការទិញយកភាគហ៊ុនចំនួន **៤៥,០៩%** របស់ ក្រុមហ៊ុន ភ្នំពេញអេសអ៊ីហ្សិត ភីអិលស៊ី និម្មិតសញ្ញា PPSP ដែលមានតម្លៃ **៦៨.៣៨៥.១០០.០០០ រៀល ឬស្មើនឹង ១៦.៧៦៥.១៦៣,០៣ ដុល្លារអាមេរិក** ត្រូវបានធ្វើឡើងជាផ្លូវការនៅ **ផ្សារមូលបត្រកម្ពុជា** ដោយប្រើប្រាស់វិធីសាស្ត្រការជួញដូរតាមការចរចា (Negotiated Trading Method) ដោយមានក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ **អេស ប៊ី អាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី** ធ្វើជាអន្តរការីមូលបត្រ។ ថ្លៃ និងព័ត៌មានលម្អិតផ្សេងទៀតនៃការជួញដូរនេះ ត្រូវបានចរចា និងព្រមព្រៀងនៅខាងក្រៅទីផ្សាររវាងភាគីអ្នកលក់ដែលជាវិនិយោគិនឯកត្តបុគ្គលក្នុងស្រុក និងភាគីអ្នកទិញដែលជាវិនិយោគិនជាស្ថាប័នក្នុងស្រុក ដោយការជួញដូរត្រូវបានប្រព្រឹត្តិឡើង និងទទួលស្គាល់ជាផ្លូវការនៅ **ផ្សារមូលបត្រកម្ពុជា** នៅក្នុងថ្ងៃនេះ។

គួររំលឹកផងដែរថា វិធីសាស្ត្រជួញដូរតាមការចរចារ គឺជាវិធីសាស្ត្រដែលអនុញ្ញាតឱ្យវិនិយោគិនមួយគូដែលបានចរចាគ្នាលើលក្ខខណ្ឌនៃការជួញដូររួចហើយ អាចដាក់បញ្ជាទិញនិងលក់ជាសម្ងាត់មក **ផ.ម.ក** ដើម្បីធ្វើការជួញដូរជាផ្លូវការ។ វិធីសាស្ត្រនេះត្រូវបានដាក់ឱ្យដំណើរការចាប់តាំងពីឆ្នាំ២០១៨ និងអនុញ្ញាតឱ្យប្រើប្រាស់ ទាំងនៅក្នុងទីផ្សារភាគហ៊ុន និងទីផ្សារសញ្ញាបណ្ណ។ កន្លងមក មានការជួញដូរភាគហ៊ុនតាមរយៈវិធីសាស្ត្រជួញដូរតាមការចរចារ ចំនួន ២៤លើក រួចមកហើយ។

**ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង÷

លោកស្រី គីម សុផានីតា ប្រធាននាយកដ្ឋាន

នាយកដ្ឋានប្រតិបត្តិការទីផ្សារ

អ៊ីម៉ែល÷ sophanita.kim@csx.com.kh